**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៤ សជណ

ក្រសួងអភិវឌ្ឍន៍ជនបទ
ចូល
លេខ [illegible] ក.អ.ជ
ថ្ងៃទី [illegible] ម៉ោង
បញ្ជូន [illegible]

## សារលិខិត

## របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ថ្លែងក្នុងឱកាសប្រារព្ធទិវាអក្ខរកម្មជាតិ អន្តរជាតិ ០៨ កញ្ញា ឆ្នាំ ២០១០

*- សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃរាជទាំងពីរគណៈ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*

*- ឯកឧត្តម លោកជំទាវ ព្រឹទ្ធាចារ្យ លោកតា លោកយាយ លោកស្រី អស់លោក*

*- អ្នកគ្រូ លោកគ្រូ ក្មួយៗសិស្សានុសិស្សជាទីស្រឡាញ់រាប់អាន និងជនរួមជាតិជាទីស្នេហា*

ក្នុងឱកាសដ៏មហោឡារិកនៃ *ទិវាអក្ខរកម្មជាតិ អន្តរជាតិ ០៨ កញ្ញា* ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមខ្ញុំព្រះករុណាខ្ញុំផ្ទាល់ សូមសម្តែងនូវក្តីរំភើបរីករាយជាមួយ បងប្អូនជនរួមជាតិ លោកស្រី អស់លោក សាស្ត្រាចារ្យ អ្នកគ្រូ លោកគ្រូ បុគ្គលិកសិក្សាព្រមទាំងក្មួយៗសិស្សានុសិស្សទាំងអស់ចំពោះការប្រារព្ធទិវាដ៏មានសារៈសំខាន់ដែលជាមោទនភាពដ៏ខ្ពង់ខ្ពស់របស់កម្ពុជាហើយ សូមឱ្យការប្រារព្ធពិធីនេះ នៅគ្រប់ទីកន្លែង ប្រព្រឹត្តទៅដោយភាពសប្បាយរីករាយ និងជោគជ័យ។

ខ្ញុំព្រះករុណាខ្ញុំ សូមសម្តែងនូវការគាំទ្រយ៉ាងពេញទំហឹង ចំពោះគ្រប់សកម្មភាពអប់រំទាំងអស់ដែលបាននិងកំពុងអនុវត្តនៅលើទឹកដីកម្ពុជា ក្នុងទិសដៅដោះស្រាយតម្រូវការរៀនសូត្ររបស់ប្រជាពលរដ្ឋគ្រប់រូប គ្រប់វ័យ រួមចំណែកកាត់បន្ថយអនក្ខរភាព។

*ទិវាអក្ខរកម្មជាតិ អន្តរជាតិ ០៨ កញ្ញា* ជាទិវាមួយដែលមានអត្ថន័យឧត្តុង្គឧត្តមជាទីបំផុត សម្រាប់ប្រទេសជាតិយើង ក៏ដូចជាពិភពលោកទាំងមូល ជាភារកិច្ចចម្បងចាំបាច់មិនអាចខ្វះបានក្នុងការធ្វើឱ្យសម្រេចគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា ពីព្រោះអក្ខរកម្មជាគន្លឹះនៃការអភិវឌ្ឍដើម្បីរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ ការអភិវឌ្ឍប្រទេសជាតិមួយឱ្យរីកចម្រើនបានលុះត្រាតែយើងខិតខំអភិវឌ្ឍធនធានមនុស្សឱ្យមានចំណេះដឹង ចំណេះធ្វើ មានកាយសម្បទាមាំមួន ប្រកបដោយសីលធម៌ល្អ និងចេះរួមរស់ដោយសុខសន្តិភាព។ ដើម្បីទទួលបានធនធានមនុស្សបែបនេះ ត្រូវតែខិតខំផ្តល់សេវាអប់រំដល់ពលរដ្ឋគ្រប់រូប គ្រប់វ័យ តាមគ្រប់រូបភាព ជាពិសេសការជំរុញឱ្យមានអត្រាអក្ខរកម្មខ្ពស់ក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាយើង។

ឆ្នាំនេះយើងប្រារព្ធទិវាអក្ខរកម្មជាតិ អន្តរជាតិ០៨កញ្ញា ក្រោមប្រធានបទ " **អក្ខរកម្មគឺជាសិទ្ធិមូលដ្ឋាន** "។ ប្រធានបទនេះបានបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋគ្រប់សញ្ជាតិនិងគ្រប់វ័យ ឱ្យទទួលបានការអប់រំពេញមួយជីវិត។ ប្រការនេះក៏ត្រូវបានធានា និងការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រាទី៦៥ ដែលបានចែងថា "រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលការអប់រំ ប្រកបដោយគុណភាព

នៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប។

រដ្ឋយកចិត្តទុកដាក់ដល់វិស័យអប់រំកាយ និងកីឡា ដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប " និងមាត្រាទី៦៦ ដែលបានចែងថា " រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍សេរីភាព ខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូប មានភ័ព្វសំណាងស្មើគ្នាក្នុងការកសាងជីវិត " ។

កន្លងមកការអប់រំក្នុងប្រព័ន្ធ និងការអប់រំក្រៅប្រព័ន្ធមានតួនាទីស្នូល និងសកម្មភាពយ៉ាងផុលផុសបំពេញឱ្យគ្នាទៅវិញទៅមក នៅគ្រប់ទីកន្លែង គ្រប់ស្ថានភាព តំបន់ជួបការលំបាក តំបន់ដាច់ស្រយាល និងតំបន់ព្រំដែន ក្នុងការផ្តល់សេវាអប់រំតាមគ្រប់រូបភាព ដល់កុមារ យុវជន យុវនារី និងប្រជាពលរដ្ឋគ្រប់រូប បានចូលរៀនដោយសមធម៌ និងរៀនប្រកបដោយគុណភាព ដោយផ្សារភ្ជាប់ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំទៅនឹងការអប់រំវប្បធម៌សន្តិភាព ការគោរពសិទ្ធិសេចក្តីថ្លៃថ្នូររបស់មនុស្ស ការគោរពគោលការណ៍សេរីភាព ប្រជាធិបតេយ្យ និងយុត្តិធម៌។

ក្នុងឱកាសដ៏ល្អប្រពៃនេះ ខ្ញុំព្រះករុណាខ្ញុំសូមថ្លែងអំណរគុណដល់គ្រប់ស្ថាប័ន អង្គការជាតិ អន្តរជាតិ ក្រសួង មន្ទីរពាក់ព័ន្ធនានា អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ សប្បុរសជន ព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យ បព្វជិតសាសនា និងប្រជាពលរដ្ឋទាំងអស់ដែលបានជួយឧបត្ថម្ភគាំទ្រយ៉ាងសកម្មដល់ការងារអប់រំក្រៅប្រព័ន្ធកន្លងមក។ ជាក់ស្តែង ជនរួមជាតិយើងទាំងចាស់ទាំងក្មេងជាច្រើនបានឆ្លងផុតពីគ្រោះមិនចេះអក្សរព្រមទាំងបានទទួលការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ជំនាញមុខរបរ និងបំណិនជីវិតសម្រាប់លើកកម្ពស់ជីវភាពរស់នៅបានកាន់តែល្អប្រសើរទៀតផង។

- *ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*
- *បងប្អូនជនរួមជាតិជាទីស្នេហា*

ដើម្បីឈានទៅសម្រេចនូវគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា ដែលបានកំណត់ថា " ធានាសម្រេចឲ្យបានការរីកចម្រើនអក្ខរជនចំនួន៥០ភាគរយថែមទៀតនៅក្នុងចំណោមអនក្ខរជនពេញវ័យនៅមុនដំណាច់ឆ្នាំ ២០១៥ ពិសេសសម្រាប់ស្ត្រីភេទ និងឱកាសស្មើភាពក្នុងការអប់រំមូលដ្ឋាន និងការអប់រំបន្តសម្រាប់ជនពេញវ័យទាំងអស់ " ស្របទៅតាមគោលការណ៍ " អប់រំសម្រាប់ទាំងអស់គ្នា ហើយទាំងអស់គ្នាសម្រាប់ការអប់រំ " ខ្ញុំព្រះករុណាខ្ញុំសូមឧទ្ទិសទិវាអក្ខរកម្ម ០៨ កញ្ញានេះ ឱ្យក្លាយទៅជាការប្តេជ្ញាចិត្តជាសកល និងអំពាវនាវដល់គ្រប់ស្ថាប័នជាតិ អន្តរជាតិ សហគមន៍ និងពលរដ្ឋកម្ពុជាគ្រប់រូប សូមយកចិត្តទុកដាក់ខ្ពស់ជាបន្តទៀតដល់ការងារអក្ខរកម្ម ក៏ដូចជាការងារអប់រំក្រៅប្រព័ន្ធដូចតទៅ៖

១. សមាជិក សមាជិការាជរដ្ឋាភិបាល និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ពេលចុះបំពេញការងារតាមមូលដ្ឋាន ត្រូវឆ្លៀតចុះឱ្យដល់ថ្នាក់អក្ខរកម្មដើម្បីលើកទឹកចិត្តនិងរួមចំណែកដោះស្រាយរាល់សំណូមពររៀនសូត្រតាមភាពជាក់ស្តែង។

២. អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវយកចិត្តទុកដាក់ចូលរួមគាំទ្រ ឱ្យបានខ្លាំងក្លាបន្ថែមទៀតក្នុងការជំរុញណែនាំប្រជាពលរដ្ឋ ដែលមិនបានរៀនសូត្រ ឬបោះបង់ការសិក្សាមានឱកាសទទួលការរៀនសូត្រជាថ្មី តាមថ្នាក់រៀនអប់រំក្រៅប្រព័ន្ធគ្រប់រូបភាព ពិសេសត្រូវខិតខំបង្កលក្ខណៈឲ្យប្រជាពលរដ្ឋដែលពិការមានលទ្ធភាពបានរៀនសូត្រផង។

៣. មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ អ្នកគ្រូ លោកគ្រូ ត្រូវបង្កើនឆន្ទៈ និងពង្រឹងក្រមសីលធម៌វិជ្ជាជីវៈ

ជាគ្រូបង្រៀន ដើម្បីចូលរួមលើកកម្ពស់ការងារអប់រំទាំងក្នុង និងក្រៅប្រព័ន្ធឱ្យមានការអភិវឌ្ឍឈានឡើង។

៤. ប្រព័ន្ធផ្សព្វផ្សាយទាំងអស់រួមមាន វិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្តី ព្រឹត្តិបត្រព័ត៌មាន ទាំងរដ្ឋទាំងឯកជនសូមជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីអានុភាពនៃការងារអក្ខរកម្មដល់ប្រជាពលរដ្ឋយើង ដើម្បីយកទៅអនុវត្តក្នុងជីវភាពរស់នៅ បានកាន់តែល្អប្រសើរ។

៥. ក្មួយៗជាសិស្ស និស្សិតតាមគ្រឹះស្ថានសាធារណៈ និងឯកជន ក្រុមយុវជនកាយរឹទ្ធិ និងក្រុមយុវជនកាកបាទក្រហមត្រូវចូលរួមជួយបង្រៀន ដោយស្ម័គ្រចិត្តដល់អ្នកមិនចេះអក្សរ នៅតាមថ្នាក់អក្ខរកម្មដែលស្ថិតក្នុងមូលដ្ឋានរបស់ក្មួយៗរស់នៅ។ ចំណែកបងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអាណាព្យាបាល ក៏សូមជួយជំរុញបងប្អូនកូនចៅឱ្យបានចូលរៀនតាមសាលារៀនចំណេះទូទៅឱ្យបានគ្រប់ៗគ្នា។ ដោយឡែកក្មួយៗ និងបងប្អូនដែលពុំទាន់ចេះអក្សរ ឬបោះបង់ការសិក្សា ចូរខិតខំប្រឹងប្រែងរៀនសូត្រនៅតាមថ្នាក់អក្ខរកម្ម ថ្នាក់សមមូលឬថ្នាក់បំប៉នជំនាញនានា ដែលនៅជិតភូមិឋានរបស់ខ្លួន។

៦. វត្តអារាម និងវិហារសាសនានានា ត្រូវចលនាព្រះសង្ឃ បព្វជិតសាសនា តាជី ដូនជីចូលរួមជំរុញកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ ឱ្យកាន់តែរីកចម្រើនតាមរយៈការទេសនាអប់រំអំពីសារប្រយោជន៍នៃការរៀនសូត្រ។

៧. ដៃគូអភិវឌ្ឍន៍ ពិសេសអង្គការមិនមែនរដ្ឋាភិបាល ត្រូវបង្កើនកិច្ចសហការ និងពង្រឹងភាពជាដៃគូ ដោយជួយឧបត្ថម្ភគាំទ្រដល់កម្មវិធីនានា របស់ការងារអប់រំក្រៅប្រព័ន្ធ ពិសេសកម្មវិធីអក្ខរកម្មផ្សារភ្ជាប់នឹងការអប់រំវិជ្ជាជីវៈឱ្យមានដំណើរការល្អជាប់ជាប្រចាំ។

៨. ប្រធានរោងចក្រសហគ្រាស និងក្រុមហ៊ុនឯកជន សូមជួយជំរុញបើកថ្នាក់អក្ខរកម្ម ឬថ្នាក់បំប៉នមុខជំនាញវិជ្ជាជីវៈផ្សេងៗដល់បងប្អូនកម្មករ កម្មការិនី ដើម្បីជាប្រយោជន៍ដល់បងប្អូនកម្មករផង និងដល់ម្ចាស់រោងចក្រសហគ្រាសផង។

សូមបងប្អូនកូនក្មួយទាំងអស់ចងចាំថា " **មានអក្ខរកម្ម មានការគិតត្រូវ មានការសម្រេចចិត្តបានត្រឹមត្រូវ ប្រទេសជាតិមានការអភិវឌ្ឍ** "។

ជាទីបញ្ចប់ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរ ដល់ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងជូនពរចំពោះបងប្អូនជនរួមជាតិ និងក្មួយៗជាទីស្រឡាញ់ទាំងអស់ សូមសមប្រកបដោយពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

07.9.10